ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា

ELECTRICITE DU CAMBODGE

លេខ :

# សេចក្តីជូនដំណឹង

## ស្តីពី ការជ្រើសរើសបុគ្គលិក

អគ្គិសនីកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណៈជនថា អគ្គិសនីកម្ពុជា ត្រូវការជ្រើសរើសបុគ្គលិក **ចំនួន ៦៨ រូប** ដើម្បីចូលបម្រើការងារ នៅអគ្គិសនីសៀមរាប នៃអគ្គិសនីកម្ពុជា ដូចខាងក្រោម :

*- **លក្ខណៈសម្បត្តិបេក្ខជន** :

១- សម្រាប់ **បុគ្គលិកបេឡា** ចំនួន ០២ រូប :

- បេក្ខជនភេទស្រី, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
- កម្រិតជំនាញ : បញ្ចប់ការសិក្សា បរិញ្ញាបត្រ ផ្នែកសេដ្ឋកិច្ច ឡើងទៅ
- ចំណេះដឹងកុំព្យូទ័រ : ចេះ Microsoft Word-Excel
- ភាសាអង់គ្លេស : ចេះអាចប្រើការបាន ជាមធ្យម
- មានរូបសម្បត្តិ ស្រស់ស្អាត

២- សម្រាប់ **បុគ្គលិកគណនេយ្យសរុប** ចំនួន ០១ រូប :

- បេក្ខជនទាំង ០២ ភេទ, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
- កម្រិតជំនាញ : បញ្ចប់ការសិក្សា បរិញ្ញាបត្រគណនេយ្យ ឬ បរិញ្ញាបត្រធនាគារ-ហិរញ្ញវត្ថុ ឡើងទៅ
- ចំណេះដឹងកុំព្យូទ័រ : ចេះ Microsoft Word-Excel
- ភាសាអង់គ្លេស : ចេះអាចប្រើការបាន ជាមធ្យម

៣- សម្រាប់ **បុគ្គលិកធ្វើវិក្កយបត្រ** ចំនួន ០២ រូប និង **បុគ្គលិកបញ្ចូលទិន្នន័យ** ចំនួន ០១ រូប សរុបចំនួន ០៣ រូប :

- បេក្ខជនទាំង ០២ ភេទ, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
- កម្រិតជំនាញ : បញ្ចប់ការសិក្សា បរិញ្ញាបត្រព័ត៌មានវិទ្យា ឡើងទៅ
- ភាសាអង់គ្លេស : ចេះអាចប្រើការបាន ជាមធ្យម

៤- សម្រាប់ **បុគ្គលិកលក់ថាមពល** ចំនួន ០២ រូប, **ភ្នាក់ងារចែកវិក្កយបត្រ** ចំនួន ០៣ រូប, **ភ្នាក់ងារស្រង់ថាមពល** ចំនួន ០៣ រូប, **ភ្នាក់ងារសម្អាតមែកឈើនិងបន្ទប់ភ្លើង** ចំនួន ០៣ រូប, **ភ្នាក់ងារជួសជុល-ថែទាំ MV** ចំនួន ០៣ រូប, **ភ្នាក់ងារជួសជុល-ថែទាំ LV** ចំនួន ០៣ រូប, **ភ្នាក់ងារបន្តចរន្ត** ចំនួន ០៦ រូប, **ភ្នាក់ងារកាត់និងភ្ជាប់ចរន្ត** ចំនួន ០២ រូប, **ភ្នាក់ងារជួសជុល** ចំនួន ០៤ រូប, **បុគ្គលិកប្រព័ន្ធបញ្ជានិងវិទ្យុ** ចំនួន ០១ រូប, **បុគ្គលិកគ្រប់គ្រងការបាត់បង់ថាមពល** ចំនួន ០១ រូប, **បុគ្គលិកប្រចាំការចែកចាយ** ចំនួន ០៤ រូប, **បុគ្គលិកបច្ចេកទេសGIS** ចំនួន ០២ រូប, **ភ្នាក់ងារថែទាំបណ្តាញ ស្នាក់ការស្រុកបន្ទាយស្រី** ចំនួន ០៨ រូប, **ភ្នាក់ងារថែទាំបណ្តាញ ស្នាក់ការស្រុកវ៉ារិន** ចំនួន ០៥ រូប, **ភ្នាក់ងារថែទាំបណ្តាញ ស្នាក់ការកំពង់ធំ** ចំនួន ០៥ រូប សរុបចំនួន ៥៥ រូប :

- បេក្ខជនភេទប្រុស, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
- កម្រិតជំនាញ : បញ្ចប់ការសិក្សា សញ្ញាប័ត្រមធ្យមបច្ចេកទេសអគ្គិសនី ឡើងទៅ
- ចំណេះដឹងកុំព្យូទ័រ : ចេះ Microsoft Word-Excel
- ភាសាអង់គ្លេស : ចេះអាចប្រើការបាន ជាមធ្យម

៥- សម្រាប់ **ភ្នាក់ងារត្រួតពិនិត្យបច្ចេកទេស** ចំនួន ០២ រូប និង **បុគ្គលិកសិក្សាគម្រោង** ចំនួន ០២ រូប សរុបចំនួន ០៤ រូប :

- បេក្ខជនទាំង ០២ ភេទ, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.I.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
- កម្រិតជំនាញ : បញ្ចប់ការសិក្សា វិស្វករអគ្គិសនី ឡើងទៅ
- ចំណេះដឹងកុំព្យូទ័រ : ចេះ AutoCAD
- ភាសាអង់គ្លេស : ចេះអាចប្រើការបាន ជាមធ្យម

៦- សម្រាប់ **បុគ្គលិកគ្រប់គ្រងបំណុល** ចំនួន ០១ រូប, **បុគ្គលិកឃ្លាំងសម្ភារបរិក្ខារបណ្តាញនិងប្រេង** ចំនួន ០១ រូប និង **បុគ្គលិកឃ្លាំងសម្ភារគ្រឿងបន្លាស់និងប្រេងឥន្ទនៈ** ចំនួន ០១ រូប សរុបចំនួន ០៣ រូប :

- បេក្ខជនទាំង ០២ ភេទ, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
- កម្រិតជំនាញ : បញ្ចប់ការសិក្សា បរិញ្ញាបត្រ ផ្នែកសេដ្ឋកិច្ច ឡើងទៅ
- ចំណេះដឹងកុំព្យូទ័រ : ចេះ Microsoft Word-Excel
- ភាសាអង់គ្លេស : ចេះអាចប្រើការបាន ជាមធ្យម ។

*- **បញ្ជាក់** : បេក្ខនារីគ្រប់ខេត្ត-ក្រុង និង បេក្ខជន ដែលមានអាសយដ្ឋានស្ថិតនៅខេត្តសាមី ប្រសិនបើលទ្ធផលពិន្ទុប្រហាក់ប្រហែលគ្នា គឺត្រូវផ្តល់អាទិភាព។

*- **ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅអគ្គិសនីកម្ពុជា បេក្ខជនត្រូវទាញយក (Download) ដោយផ្ទាល់ពីក្នុងគេហទំព័ររបស់អគ្គិសនីកម្ពុជា គឺ : www.EDC.com.kh ត្រង់ចំណុចព័ត៌មានវិជ្ជាជីវៈ ដោយចុចលើ ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅអគ្គិសនីកម្ពុជា ។**

*- **<u>បេក្ខជនត្រូវមកដាក់ពាក្យ និង ភ្ជាប់មកជាមួយនូវ</u>** :

| | |
|---|---|
| - ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារ នៅអគ្គិសនីកម្ពុជា | ចំនួន ០១ ច្បាប់ |
| - ប្រវត្តិរូបសង្ខេប មានបិទរូបថត ៤ x ៦ | ចំនួន ០១ ច្បាប់ |
| - កិច្ចសន្យា សម្រាប់បំពេញពាក្យសុំចូលបម្រើការងារ និងកិច្ចសន្យាការងារ | ចំនួន ០១ ច្បាប់ |
| - សលាកប័ត្របេក្ខជន | ចំនួន ០១ ច្បាប់ |
| - ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ និងសញ្ញាប័ត្រជំនាញ មានបញ្ជាក់ពីអាជ្ញាធរដែនដី | ចំនួន ០១ ច្បាប់ |
| - តារាងពិន្ទុ (TRANSCRIPT) | ចំនួន ០១ ច្បាប់ |

*- **ចំពោះបែបបទមួយចំនួនទៀត ដូចមានចែងក្នុងឧបសម្ព័ន្ធ I នៃលក្ខន្តិកៈបុគ្គលិកអគ្គិសនីកម្ពុជា បេក្ខជនប្រឡងជាប់ មានកាតព្វកិច្ចបំពេញបន្ថែម ។**

*- **<u>ទីកន្លែងទទួលពាក្យ</u>** : **នៅអគារ B ជាន់ទី១ ការិយាល័យបុគ្គលិក នៃអគ្គិសនីកម្ពុជា**
ចាប់ពីថ្ងៃផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ រៀងរាល់ថ្ងៃធ្វើការ

- ពេលព្រឹក ចាប់ពីម៉ោង ០៨ : ០០ ដល់ម៉ោង ១១ : ៣០
- ពេលល្ងាច ចាប់ពីម៉ោង ១៤ : ០០ ដល់ម៉ោង ១៧ : ០០ ។

*- **<u>ព័ត៌មានផ្សេងៗ</u>** : សូមអញ្ជើញមកទាក់ទង ការិយាល័យរដ្ឋបាល ទីស្នាក់ការកណ្តាល អគ្គិសនីកម្ពុជា ឬតាមរយៈលេខទូរស័ព្ទ ០២៣ ៧២៣ ៩៧១ និង ០២៣ ៧២៤ ៧៧១។

រាជធានីភ្នំពេញ,ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៧

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**
**អគ្គនាយករង**

ELECTRICITE DU CAMBODGE

**អេង_គន្ធា**

**<u>បញ្ជាក់</u>**
- សេចក្តីជូនដំណឹងនេះ ធ្វើការផ្សព្វផ្សាយជាផ្លូវការតាមរយៈគេហទំព័ររបស់ អគ្គិសនីកម្ពុជា គឺ : www.EDC.com.kh ត្រង់ចំណុច " ព័ត៌មានវិជ្ជាជីវៈ "។